**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ :....................

## សូមគោរពជូន

## ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។**

**កម្មវត្ថុ ៖** សំណើសុំគោលការណ៍អនុញ្ញាតឆ្លាក់ត្រាមូល និងប្រើប្រាស់ត្រា ជានិមិត្តសញ្ញារបស់គណៈកម្មាធិការជាតិ និងគណៈកម្មាធិការរាជធានីខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**យោង ៖** ព្រះរាជក្រឹត្យលេខនស/រកត/០៦១៤/៨០៨ចុះថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០១៤ ស្ដីពីការបង្កើត គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរព ជម្រាបជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបថាយោងព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាយន្តការអន្តរស្ថាប័ន ថ្នាក់ជាតិ សម្រាប់ជាសេនាធិការ ជូនរាជរដ្ឋាភិបាលក្នុងការងារប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃអំពើជួញដូរ អំពើធ្វើអាជីវកម្ម កេងប្រវ័ញ្ច លើមនុស្សគ្រប់រូបភាព ជាពិសេសលើស្ត្រីនិងកុមារ ។ ដូចនេះ នាងខ្ញុំសូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់តាម កម្មវត្ថុខាងលើ ដើម្បីបានប្រើប្រាស់ត្រាមូល និងនិមិត្តសញ្ញាសម្គាល់ជាផ្លូវការរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរសេរអក្សរកាត់ **គ.ជ.ប.ជ** គណៈកម្មាធិការរាជធានីប្រឆាំងអំពើជួញដូរមនុស្ស សរសេរអក្សរ កាត់ **គ.រ.ប.ជ** និងគណៈកម្មាធិការខេត្តប្រឆាំងអំពើជួញដូរមនុស្ស សរសេរអក្សរកាត់ **គ.ខ.ប.ជ** នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលមានគំរូដូចជូនភ្ជាប់មកជាមួយ ។

អាស្រ័យដូចបានគោរពជំរាបជូនខាងលើ សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី 24 ខែ 07 ឆ្នាំ២០១៤

**រដ្ឋលេខាធិការទទួលបន្ទុក**

25/07/14

ស ១២១

ជូ_ប៊ុនអេង